# *របកគំហើញផូស៊ីលនៅតំបន់ភ្នំសំពៅ*

*ភ្នំសំពៅស្ថិតនៅ ឃុំភ្នំសំពៅ ស្រុកបាណន់ ខេត្តបាត់ដំបង ដោយយើងអាចធ្វើដំណើរចេញពីខេត្តបាត់ដំបងតាមផ្លូវលេខ៥៧ មានចម្ងាយប្រមាណ ១២គីឡូម៉ែត្រ។ បច្ចុប្បន្នតំបន់នេះមានប្រជាជនរស់នៅពាសពេញ និងជាតំបន់ដ៏មានសក្តានុពលខាងផ្នែកទេសចរណ៍ធម្មជាតិ ដ្បិតអីទីតាំងនេះសំបូរដោយភ្នំថ្មកំបោរ និងមានរូងភ្នំជាច្រើនដូចជាល្អាងផ្កាស្លា ល្អាងខ្យល់ ល្អាងស្ពានីយ។ ភ្នំថ្មកំបោរជាច្រើនដែលយើងឃើញនៅជុំវិញតំបន់ភ្នំសំពៅនោះមានដូចជា* ***ភ្នំក្រពើ, ភ្នំសំពៅ, ភ្នំក្តោងសំពៅ, ភ្នំទ្រុងមាន់ទ្រុងទា, ភ្នំរំសាយសក់, សុវណ្ណមសា, ភ្នំសង់ក្បាល*** *(នៅជិតស្រុកមង្គលបុរីសព្វថ្ងៃ ប៉ុន្តែអ្នកស្រុកហៅក្លាយមកថា "ភ្នំសង់ក្បាន" ទៅវិញ),* ***ភ្នំសង់ក្បាន*** *និង****ភ្នំក្រពាយនាង*** *តែសព្វថ្ងៃគេហៅក្លាយមកថា "****ភ្នំបន្ទាយនាង****"។ ហើយម្យ៉ាងការហៅឈ្មោះភ្នំទាំងនេះ ក៏មានរឿងនិទានរៀបរាប់ពីមូលហេតុនៃការកកើតភ្នំទាំងនេះផងដែរ[១]។ ក្នុងអត្ថបទនេះនឹងបង្ហាញអំពីការរកឃើញប្រភេទផូស៊ីលដ៏កម្រនឹងជួបប្រទះនៅតំបន់ភ្នំសំពៅ ហើយនឹងធ្វើការស្វែងយល់ថាតើភ្នំសំពៅពិតជាមានទំនាក់ទំនងនឹងសមុទ្រយ៉ាងដូចម្តេច?*

*ភ្នំសំពៅជាប្រភេទភ្នំថ្មកំបោរ ដែលមានអតីតកាលនៅក្នុងសមុទ្រ។ ភ្នំនេះមានអាយុកាលនៅស័កទី១* Paleozoic *ក្នុងសម័យ* Permian *ដែលមានអាយុកាល ២៥១-២៩៩ លានឆ្នាំមុន[២]។ ហើយប្រទេសកម្ពុជាសម័យនោះអាចនៅជាសមុទ្រនៅឡើយ ដោយយោងតាមការសិក្សាស្រាវជ្រាវថ្មីៗ ស្តីអំពីផូស៊ីលនៅកម្ពុជារបស់នាយកដ្ឋានតំបន់បេតិកភណ្ឌ អគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន នៃក្រសួងបរិស្ថាន។ យើងបានរកឃើញភស្តុតាងមួយចំនួនដែលអាចបញ្ជាក់ថា ភ្នំសំពៅពិតជាធ្លាប់នៅក្នុងសមុទ្រ។ នៅតាមដងផ្លូវឡើងទៅកាន់ព្រះវិហារមួយនៅលើកំពូលភ្នំសំពៅ យើងបានជួបប្រទះពពួកសត្វសមុទ្រដែលកប់នៅក្នុងថ្ម ដោយពពួកសត្វប្រភេទនេះមានឈ្មោះថា* Brachiopods[៣] *(រូបលេខ១) ដែល*

---

[១] *ពុទ្ធសាសនបណ្ឌិត្យ ប្រជុំរឿងព្រេងខ្មែរភាគ៥ ទំព័រ១៣៧-១៤២*

[២] *ផែនទី ភូគព្ភសាស្ត្រ នៃព្រះរាជាណាចក្រកម្ពុជា បោះពុម្ពឆ្នាំ២០១០*

[៣] 2018, Miles Kelly, 6000 Awesome Facts, P133

*អត្ថបទដោយ៖ លឹម វណ្ណច័ន្ទ*

ជាប្រភេទសត្វសមុទ្រមានសណ្ឋានប្រហាក់ប្រហែលនឹងងាវបច្ចុប្បន្ន តែវាមានរូបរាងស្ទើរមូល និងមានសំបកធ្ងួតៗ។ ពពួកនេះស្ថិតនៅក្នុងក្រុមជាមួយសត្វកាឈីវ (រូបលេខ២) ដែលមានសំបកដូចគ្រំតែមានជើងមួយដុះចេញមក ក្រុមនេះមានច្រើននៅស័កទី១ ចាប់ពីស័កទី២ និងបន្តមកពេលបច្ចុប្បន្នមានតិចតួចដែលនៅរស់រានមានជីវិត។ ក្នុងពេលបច្ចុប្បន្ននៅប្រទេសកម្ពុជា យើងសង្កេតឃើញមានពួកកាឈីវដែលនៅមានលើទីផ្សារលក់គ្រឿងសមុទ្រ[៤] តែក៏មិនទាន់ដឹងថានៅក្នុងសមុទ្រនៃប្រទេសកម្ពុជានៅមានប៉ុន្មានប្រភេទនោះទេ? ដ្បិតពួកកាឈីវជាប្រភេទសត្វដ៏ចំណាស់មួយ។ ក្រៅពីនេះយើងក៏បានជួបប្រទះពពួកផ្កាថ្ម២ប្រភេទផ្សេងគ្នាដែលបានកប់ជាប់នៅក្នុងថ្មផ្នែកនៃកំពូលភ្នំ (រូបលេខ៣-៤)។ ពពួកខ្លះទៀតយើងក៏ពុំទាន់បានកំណត់អត្តសញ្ញាណវាបាននៅឡើយ ដូចជាពពួកផូស៊ីលម៉្យាងមានរាងមូលដូចគ្រាប់ឃ្លី មានទំហំប៉ុនកូនដៃ ផ្នែកខាងក្នុងមានរាងជាស្រទាប់ដូចជាវង្វង់ច្រើនជាន់(រូបលេខ៥)។ ផូស៊ីលមួយប្រភេទទៀតមានរាងដូចគ្រាប់អង្ករ ដែលពេលខ្លះគេច្រឡំថាវាជាគ្រាប់ធញ្ញជាតិ និងពេលខ្លះគេថាពួកនេះជាផូស៊ីលស្រូវ ដែលយើងឃើញកប់ជាប់នឹងថ្មនៅភ្នំសំពៅដែរ។ យើងពិបាកក្នុងការជឿថាទឹកសមុទ្រអាចឡើងដល់កំពូលភ្នំសំពៅ តែជាការពិតណាស់សណ្ឋានដីមានការប្រែប្រួល ខ្លះក៏ងើបឡើង ឬស្រុតចុះក្នុងពេលណាមួយ។ រីឯសណ្ឋានដីភ្នំសំពៅក៏ដូចគ្នា មានន័យថាក្នុងពេលមួយក៏មានការរុញឡើងនៃស្រទាប់ផែនដីផងដែរ(រូបលេខ៧)។ ដូច្នេះយើងអាចយល់បានថាពពួកសត្វដែលយើងឃើញកកនៅជាប់ភ្នំនេះ ដើមឡើយក្នុងពេលដែលពួកវានៅមានជីវិត អាចស្ថិតនៅកម្រិតណាមួយដែលទាបជាងពេលបច្ចុប្បន្ន។ ភ្នំទាំងឡាយដែលមានរៀបរាប់ខាងលើ ដូចជា ភ្នំសំពៅ ភ្នំក្តោង ភ្នំបន្ទាយនាង(ខេត្តបន្ទាយមានជ័យ) គឺជាស្ថានីយផូស៊ីលសត្វសមុទ្រ ហើយបង្ហាញទាំងនេះជាពត៌មានបឋមនៅឡើយ។

[៤] រដ្ឋបាលជលផល ២០០៨ :៩៥

អត្ថបទដោយ៖ លឹម វណ្ណចន្ទ

## ឯកសារយោង

ពុទ្ធសាសនបណ្ឌិត្យ.
ប្រជុំរឿងព្រេងខ្មែរភាគ៥ ទំព័រ១៣៧-១៤២
ផែនទី ភូគព្ភសាស្ត្រ នៃព្រះរាជាណាចក្រកម្ពុជា បោះពុម្ពឆ្នាំ២០១០
រដ្ឋបាលជលផល.
២០០៨. មគ្គុទេសក៍អំពីធនធានជលផលសមុទ្រនៅក្នុងប្រទេសកម្ពុជា, ទំព័រ៩៥
Miles Kelly.
2018. 6000 Awesome Facts, P133



រូបលេខ១៖ ប្រភេទមួយនៃពពួក Brachiopods



រូបលេខ២៖ កាឈើរ

អត្ថបទដោយ៖ លឹម វណ្ណច័ន្ទ



រូបលេខ៣៖ ផ្កាថ្មមួយប្រភេទ



រូបលេខ៤៖ ផ្កាថ្ម មួយប្រភេទ

អត្ថបទដោយ៖ លឹម វណ្ណច័ន្ទ



រូបលេខ៥៖ ផូស៊ីលមានរូបរាងដូចកូនឃ្មី



រូបលេខ៦៖ ការរុញឡើងនៃស្រទាប់ថ្មភ្នំសំពៅ និងភ្នំក្ដោង

អត្ថបទដោយ៖ លឹម វណ្ណច័ន្ទ